# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីទោសនៃការប្រព្រឹត្តល្បែងស៊ីសង

**Website: www.hoksavann.org**

ថ្ងៃទី៣១ តុលា ២០០៤

ការលេងល្បែងដែលមានទោស គឺសំដៅយកល្បែងស៊ីសងដាក់ប្រាក់កាសឬវត្ថុផ្សេងៗ បើលេងកីឡាហាត់ប្រាណ លេងកីឡាជាមិត្តភាព ពុំមានទោសទេ ។ ល្បែងដែលមានទោសដូចជាល្បែងបៀអាប៉ោង ល្បែងកាស៊ីណូជាដើម ។ ល្បែងស៊ីសងមានទោស៦យ៉ាង ៖

១- កាលឈ្នះរមែងបង្កឲ្យកើតពៀរ ៖ សេចក្ដីថា បើអ្នកលេងឈ្នះ អ្នកចាញ់ពុំសប្បាយចិត្តឡើយ រមែងរកមធ្យោបាយយកឈ្នះវិញ ហើយអ្នកឈ្នះអាចគ្រោះថ្នាក់ពីចោរប្លន់ ។

២- កាលចាញ់រមែងសោកស្ដាយទ្រព្យ ៖ គឺអ្នកចាញ់តែដេកកើតទុក្ខ ។

៣- ទ្រព្យសម្បត្តិតែងវិនាស ៖ ឡេកម្រឃើញអ្នកលេងល្បែងមានកំណើត មានទ្រព្យសម្បត្តិដោយការលេងល្បែងឡើយ បើនៅប្រទេសកម្ពុជា ឮតែលក់គោលក់ក្របីលក់ផ្ទះសំបែង ឈ្លោះទាស់ទែងប្ដីប្រពន្ធដោយសារការអស់ទ្រព្យ គឺខាតទាំងចុងខាតទាំងដើម មានអ្នកចាញ់ខ្លះធ្វើជាចោរលួចប្លន់ មានអ្នករាជការខ្លះអាចប្រព្រឹត្តអំពើពុករលួយ ។

៤- មិនមានអ្នកណាមួយជឿពាក្យ ៖ គឺគេពុំជឿពាក្យអ្នកលេងល្បែងឡើយ ព្រោះគេខ្លាចបោកគេយកប្រាក់ទៅលេងល្បែង ។

៥- ជាទីមើលងាយនៃមិត្តភក្ដិ ៖ មិត្តសំឡាញ់មិនឲ្យតម្លៃ និងពោលរិះគន់និងមិនជឿទុកចិត្តមិត្តដែលលេងល្បែងឡើយ ។

៦- មិនមានសប្បុរសចងជាមិត្ត ៖ ធម្មតាលោកអ្នកសប្បុរសពុំសេពគប់មនុស្សអាក្រក់ មានមនុស្សលេងល្បែងជាដើមឡើយ ។

ទោសទាំង៦នេះ ឃើញក្នុងបច្ចុប្បន្នទាន់ភ្នែក ។ ពាក្យខ្មែរក៏ពោលថា លេងល្បែងតែងវិនាស ។ នៅក្នុងបរាភវសូត្រគម្ពីររបស់ពុទ្ធសាសនា និយាយអំពីល្បែងបីប្រការនាំឲ្យវិនាស លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនោះហៅមហាឆ្កួតក្រៃកន្លង ។ ព្រះពុទ្ធជាម្ចាស់បង្រៀនឲ្យមនុស្សខំប្រឹងប្រែងធ្វើការងារតែប្រកបតែការងារល្អ ការងារដែលប្រកបដោយធម៌សុចរិត ជៀសវាងការងារទុច្ចរិត និងការងាររបៀបផ្សងព្រេង មានការលេងល្បែងភ្នាល់ជាដើម ។

ប្រទេសកម្ពុជាសព្វថ្ងៃ មានធ្វើវិនិយោគទុនបើកបនល្បែងកាស៊ីណូជាច្រើនកន្លែង នៅទីក្រុងភ្នំពេញនិងនៅតាមព្រំដែនខ្មែរ-ថៃ និងបំរុងបើកកាស៊ីណូនៅតាមព្រំដែនខ្មែរ-វៀតណាមទៀត ។ តាមគំរោងរបស់រាជរដ្ឋាភិបាលខ្មែរថា កាស៊ីណូទាំងនោះអនុញ្ញាតឲ្យបង្កើតសំរាប់តែជនបរទេសលេងប៉ុណ្ណោះ ប៉ុន្តែគេសង្កេតឃើញថាខ្មែរក៏មានទៅលេងជាមួយជនបរទេសដែរ ។ គួរឲ្យស្ដាយមួយទៀត មានអាគារកាស៊ីណូមួយនៅទីក្រុងភ្នំពេញខ្ពស់ស្កឹមស្កៃជាងព្រះបរមរាជវាំង ដែលជាស្ថាប័នកំពូលរបស់ខ្មែរទៅទៀត ។ ក្រៅពីនោះទៀត តាមសារពត៌មានរស្មីកម្ពុជាបានផ្សាយនៅថ្ងៃទី៩សីហា២០០៤និយាយថា ប្រទេសកម្ពុជាជាពិភពល្បែងឆ្នោតធំជាងគេនៅលើពិភពលោក ។ មានក្រុមហ៊ុនបរទេសលេងឆ្នោត ៦ ចេញឆ្នោតទាំងយប់ទាំងថ្ងៃ មានលេខ២ខ្ទង់ លេខ៣ខ្ទង់ ក្នុង១ថ្ងៃចេញ១៣ដង ។ ក្រុមហ៊ុនទាំង៦នេះបានចំណេញកើបយកប្រាក់ពីប្រជាពលរដ្ឋខ្មែរក្នុង១ឆ្នាំបានចំនួន២លានដុល្លារសហរដ្ឋអាមេរិក ។ អាជ្ញាប័ណ្ណអនុញ្ញាតច្បាប់ឲ្យក្រុមហ៊ុនបរទេសទាំង៦បើកលេងឆ្នោតនេះ គឺចេញពីរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។ ដូច្នេះការអនុញ្ញាតច្បាប់បើកល្បែងឆ្នោតនេះ គឺចេញពីរដ្ឋអំណាចជាន់ខ្ពស់តែម្ដង ប៉ុន្តែគេពុំដឹងថា រដ្ឋអំណាចជាន់ខ្ពស់នេះបានប្រាក់ប៉ុន្មានពីក្រុមហ៊ុនទាំងនេះ បានជាសុខចិត្តឲ្យបើកល្បែងនេះ ទោះបីដឹងថា គេកើបយកប្រាក់ពីប្រជាពលរដ្ឋរបស់ខ្លួន ដែលកំពុងក្រីក្រ ក្នុង១ឆ្នាំៗរាប់លានដុល្លារទៅប្រទេសគេក៏ដោយ ។ ភស្ដុតាងនេះបញ្ជាក់ថា រាជរដ្ឋាភិបាលខ្មែរមិនត្រឹមតែពុំបំបាត់ល្បែងស៊ីសងទេ ផ្ទុយទៅវិញបានបើកល្បែងស៊ីសងនេះតែម្ដង ដែលផ្ទុយនឹងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលពោលថា ល្បែងតែងវិនាស ។ ក្នុងពិភពលោក ប្រទេសខ្លះបានបើកឲ្យលេងកាស៊ីណូដែរ ប៉ុន្តែប្រទេសគេមានការលូតលាស់គ្រប់វិស័យ ស្ថាប័នរឹងមាំ ច្បាប់ទម្លាប់ត្រឹមត្រូវ ប៉ុន្តែប្រទេសកម្ពុជានៅទាន់ខ្សោយគ្រប់វិស័យ បើបើកឲ្យលេងល្បែងស៊ីសង ផលវិបាកអាក្រក់ធ្លាក់ទៅលើប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋខ្លះងប់នឹងល្បែង ហើយជាប្រភពនៃការទាស់ទែងខ្វែងគំនិតគ្នាក្នុងក្រុមគ្រួសារ និងនាំឲ្យកើតចោរលួចចោរប្លន់ផង ។ ដោយឃើញផលវិបាកអាក្រក់នេះ នៅប្រទេសខ្លះដូចជាប្រទេសនៅជិតខាងខ្មែរ គឺប្រទេសថៃគេពុំអនុញ្ញាតច្បាប់ឲ្យបើកល្បែងស៊ីសងឡើយ ។

ដោយប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា ហើយពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាខ្លឹមសារសំរាប់អប់រំឲ្យមនុស្សមានតម្លៃថ្លៃថ្នូរ មានឲ្យវៀរចាកអំពើអបាយមុខ ដែលជាប្រធាននៃសេចក្ដីវិនាសទាំងបី គឺល្បែងស្រីល្បែងស្រានិងល្បែងស៊ីសងជាដើម គួររាជរដ្ឋាភិបាលខ្មែរពិចារណា ហើយលប់អាជ្ញាប័ណ្ណល្បែងស៊ីសងទាំងអស់ ហើយងាកមករកវិនិយោគទុនក្រៅពីនេះ ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យចំរើនលូតលាស់វិញ ។៚

( កកន ៖ កាលសម័យសង្គមរាស្ត្រនិយម លោកសីហនុក៏បានអនុញ្ញាតបើកកាស៊ីណូរដ្ឋ និងលេងល្បែងនៅពេលបុណ្យចូលឆ្នាំ ។ ការបំពានលើសាសនារដ្ឋនេះ បានហូរចេញមកពីថ្នាក់កំពូលជាតិតែម្ដង ។ នេះពុំគ្រាន់តែជាសញ្ញាបរាជ័យនៃនយោបាយសង្គមរាស្ត្រនិយមប៉ុណ្ណោះទេ តែជាការចាប់ផ្ដើមស្រុតចុះ នៃកិត្យានុភាពរបបរាជានិយមខ្មែរដ៏មានចំណាស់រាប់សតវត្សមកហើយនោះថែមទៀតផង ។ អំពើដឹកនាំស្រុកធ្លាក់ទៅក្នុងអបាយមុខនេះ គឺជាការទទួលខុសត្រូវរបស់លោកសីហនុយ៉ាងពិតប្រាកដណាស់ ។ គេពុំអាចបន្ទោសហ៊ុន-សែនតែម្នាក់គត់បានទេ តាមពិតទៅ ហ៊ុន-សែនគាត់យកគំរូតាមលោកសីហនុទេតើ ! ) ។៚